# មហាសុខជាតក



ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **ធុមោ យថា ហោតិ** ដូច្នេះជាដើម ។

បានឮមកថា ភិក្ខុនោះកាន់យកកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា ហើយទៅនៅក្នុងព្រៃដែលអាស្រ័យនឹងបច្ចន្តគ្រាមមួយ ក្នុងកោសលជនបទ ។ មនុស្សទាំងឡាយតាក់តែងកសាងទីនៅក្នុងពេលយប់ ទីនៅក្នុងថ្ងៃដល់លោក និងធ្វើសេនាសនៈក្នុងទីដែលដល់ព្រមដោយគមនាគម ហើយទំនុកបម្រុងដោយសេចក្តីគោរព ។ កាលភិក្ខុនោះកំពុងចាំ ក្នុងខែដំបូងនោះឯង ក៏មានភ្លើងឆេះស្រុក សូម្បីត្រឹមតែគ្រាប់ពូជរបស់មនុស្សទាំងឡាយ ក៏មិនមានសេសសល់ ។ ពួកគេទើបមិនអាចនឹងថ្វាយបិណ្ឌបាតប្រណីតដល់ភិក្ខុនោះ ។ ភិក្ខុនោះ សូម្បីបានសេនាសនៈសប្បាយ តែកាលលំបាកដោយចង្អាន់បិណ្ឌបាត ទើបមិនអាចនឹងញ៉ាំងមគ្គ និងផលឲ្យកើតឡើង ។

លំដាប់នោះ ដោយកាលកន្លងទៅ ៣ ខែ ភិក្ខុនោះក៏ធ្វើដំណើរមក ដើម្បីនឹងថ្វាយបង្គំព្រះសាស្តា ។ ព្រះសាស្តាធ្វើបដិសណ្ឋារៈនឹងភិក្ខុនោះ ហើយត្រាស់សួរថា ម្នាលភិក្ខុ អ្នកមិនលំបាកដោយបិណ្ឌបាតទេឬ សេនាសនៈជាទីសប្បាយទេឬ ។ ភិក្ខុនោះប្រាប់សេចក្តីនោះ ។ ព្រះសាស្តាដឹងថា សេនាសនៈសប្បាយមានដល់លោក ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា សមណៈ កាលមានសេនាសនៈជាទីសប្បាយហើយ គួរលះសេចក្តីល្មោភក្នុងអាហារចេញ ត្រូវបរិភោគបច្ច័យតាមដែលមានបាននោះឯង គួរដើម្បីនឹងធ្វើសមណធម៌ដោយសេចក្តីសន្តោស ។ បោរាណកបណ្ឌិតទាំងឡាយ សូម្បីកើតក្នុងកំណើតសត្វតិរច្ឆានទំពាស៊ីកម្ទេចឈើស្ងួតដែលខ្លួននៅ លះសេចក្តីល្មោភក្នុងអាហារ ជាអ្នកសន្តោស មិនទម្លាយមិត្តធម៌ មិនទៅកាន់ទីដទៃ ព្រោះហេតុអ្វី អ្នកទើបគិតថា បិណ្ឌបាតតិច សៅហ្មង ហើយលះសេនាសនៈសប្បាយ ដូច្នេះហើយ ព្រះអង្គដែលភិក្ខុទូលអារាធនាហើយ ទើបនាំអតីតនិទានមកថា

ក្នុងអតីតកាល នៅទីងប្រាំងទន្លេគង្គាក្នុងព្រៃហិមពាន្ត មានសត្វសេកច្រើនសែន នៅក្នុងព្រៃឧទុម្ពរ (ព្រៃល្វារ) មួយ ។ បណ្តាសេកទាំងនោះ ស្តេចសេកមួយ កាលដើមឈើរបស់ខ្លួនអស់ផ្លែហើយ វត្ថុណាដែលនៅសល់ ទោះជាពន្លកក្តី ស្លឹកក្តី សំបកក្តី ក្រម៉ក្តី ក៏ទំពាស៊ីវត្ថុទាំងនោះ ផឹកទឹកទន្លេគង្គា ជាអ្នកប្រាថ្នាតិច និងមានសេចក្តីសន្តោសដ៏ក្រៃលែង មិនទៅកាន់ទីដទៃ ។ ព្រោះគុណនៃភាពជាអ្នកប្រាថ្នាតិច និងសន្តោសរបស់ស្តេចសេកនោះ ភពរបស់សក្កទេវរាជក៏កម្រើកញាប់ញ័រ ។ ស្តេចសក្កៈកាលពិចារណាមើល បានឃើញហេតុនោះ ដើម្បីនឹងសាកល្បងចិត្តរបស់សេកនោះ ព្រះអង្គក៏បណ្តាលឲ្យដើមឈើនោះ ស្វិតក្រៀមស្រពោនដោយអានុភាពរបស់ខ្លួន ។ ដើមឈើបានក្លាយជាដង្គត់ កាលខ្យល់បក់មកត្រូវ ក៏មានប្រហោងតូចធំ តាំងនៅដូចជាមានគេមកវាយ ។ លម្អិតទាំងឡាយហូរចេញតាមប្រហោងដើមឈើនោះ ។ សេកសុវរាជបរិភោគលម្អិតនោះផឹកទឹកក្នុងទន្លេគង្គា មិនទៅកាន់ទីដទៃ មិនអើពើនឹងខ្យល់និងកម្តៅ អង្គុយលើដង្គត់ដើមឧទុម្ពរ ។ សក្កទេវរាជបានដឹងភាពជាអ្នកប្រាថ្នាតិចដ៏ក្រៃលែងរបស់សេកនោះហើយ ទ្រង់គិតថា យើងនឹងមក ឲ្យស្តេចសេក

*សម្តែងគុណនៃមិត្តធម៌ ហើយនឹងឲ្យពរដល់សេកនោះ និងធ្វើឲ្យដើមឧទុម្ពរនោះមានផ្លែរហូត ដូច្នេះហើយ ទើបព្រះអង្គក្លែងខ្លួនជាស្តេចហង្ស ធ្វើនាងសុជាអសុរកញ្ញាឲ្យនៅខាងមុខ យាងមកព្រៃឧទុម្ពរនោះ អង្គុយលើមែកដើមឈើមួយ ក្នុងទីមិនឆ្ងាយ កាលនឹងញ៉ាំងកថាឲ្យតាំងឡើងជាមួយនឹងស្តេចសេកនោះ ទើបពោលគាថាទី ១ ថា*

**ទុមោ យទា ហោតិ ផលូបបន្នោ, ភុញ្ជន្តិ នំ វិហង្គមា សម្បតន្តា;**
**ខីណន្តិ ញត្វាន ទុមំ ផលច្ចយេ, ទិសោទិសំ យន្តិ តតោ វិហង្គមា។**

***កាលណា ឈើមានផ្លែបរិបូណ៌ ពួកសត្វស្លាបក៏ហើរសំដៅទៅបរិភោគផ្លែឈើនោះ លុះពួកសត្វស្លាបបានដឹងថា ឈើអស់ផ្លែហើយ ក៏ហើរចេញអំពីដើមឈើនោះ ទៅកាន់ទិសផ្សេងៗ ក្នុងវេលាជាទីអស់ទៅនៃផ្លែ ។***

*អ្នកសិក្សាគប្បីជ្រាបសេចក្តីនៃគាថានោះថា បពិត្រស្តេចសេក កាលណាដើមឈើដែលមានផ្លែបរិបូណ៌ កាលនោះ ហ្វូងបក្សីទាំងឡាយនាំគ្នាមកបរិភោគផ្លែនោះ អំពីមែកមួយទៅមែកមួយ កាលដឹងថា ដើមឈើនេះអស់ផ្លែហើយ ហ្វូងបក្សីនាំគ្នាហើរចេញពីដើមនោះ ទៅកាន់ទិសតូចទិសធំ ។*

*កាលពោលយ៉ាងនេះហើយ ដើម្បីបញ្ជូនស្តេចសេកនោះ ចេញពីទីនោះ ស្តេចហង្សទើបពោលគាថាទី ២ ថា*

**ចរ ចារិកំ លោហិតតុណ្ឌ មា មរិ, កឹ ត្វំ សុវ សុក្ខទុមម្ហិ ឈាយសិ;**
**តទិង្ឃ មំ ព្រូហិ វសន្តសន្និភ, កស្មា សុវ សុក្ខទុមំ ន រិញ្ចសិ។**

***ម្នាលសេកមានចំពុះក្រហម អ្នកចូរត្រាច់ទៅកាន់ចារិក កុំឲ្យខ្លួនអ្នកស្លាប់ឡើយ ម្នាលសេក ម្តេចក៏អ្នកនៅសញ្ជប់សញ្ជឹងលើដើមឈើងាប់ (នេះ) ម្នាលសេកមានសម្បុរខៀវស្រងៀងនឹងឈើ ក្នុងវស្សន្តរដូវ យើងសូមដាស់តឿនអ្នក អ្នកចូរថាមកមើល ព្រោះហេតុអ្វី ក៏បានជាអ្នកមិនលះបង់នូវឈើងាប់នេះ ។***

*បណ្ដាបទទាំងនោះ បទថា* **ឈាយសិ** *សេចក្ដីថា ព្រោះហេតុអ្វី អ្នកទើបសញ្ចប់សញ្ចឹង បិតនៅលើកំពូលដើមឈើស្ងួត ។ បទថា* **កុស្ស** *សេចក្ដីថា ជានិបាត ចុះក្នុងអត្ថដាស់តឿន ។ បទថា* **វសេន្តសន្និក** *សេចក្ដីថា ក្នុងរដូវភ្លៀង ព្រៃសណ្ឋៈ នឹងមានពណ៌ខៀវដូចដេរដាសដោយហ្វូងសេក ព្រោះហេតុនោះ ស្ដេចហង្សទើបហៅស្ដេចសេកថា វសន្ត-សន្និកៈ ។ បទថា* **ន វិញាសិ** *ប្រែថា អ្នកមិនលះ ។*

*លំដាប់នោះ ស្ដេចសេកពោលថា បពិត្រហង្ស ខ្ញុំមិនលះដើមឈើនេះ ព្រោះភាពជាកតញ្ញូកតវេទី របស់ខ្លួន ដូច្នេះទើបពោល ២ គាថា ថា*

**យេ វេ សខីនំ សខារោ ភវន្តិ, បាណច្ចយេ ទុក្ខសុខេសុ ហំស;**
**ខីណំ អខីណម្បិ ន តំ ជហន្តិ, សន្តោ សតំ ធម្មមនុស្សរន្តា។**

*ម្នាលហង្ស ពួកសប្បុរសណា រលឹករឿយ ៗ នូវធម៌របស់ពួកសប្បុរស លោកជាសម្លាញ់និងពួកសម្លាញ់ ( ទៅវិញទៅមកហើយ) ពួកសប្បុរសនោះ សូម្បីដល់នូវការអស់ទៅនៃជីវិត ក៏មិនលះបង់សម្លាញ់នោះចោល ដោយគិតថាអស់ ឬមិនអស់ ក្នុងកាលដែលបានសុខ និងទុក្ខឡើយ ។*

**សោហំ សតំ អញ្ញតរោស្មិ ហំស, ញាតី ច មេ ហោតិ សខា ច រុក្ខោ;**
**តំ ឆុស្សហោ ជីវិកាត្ថោ បហាតុំ, ខីណន្តិ ញត្វាន ន ហេស ធម្មោ។**

*ម្នាលហង្ស ខ្ញុំជាសប្បុរសដែរ ដើមឈើនេះ ទុកជាញាតិ ឬជាសម្លាញ់របស់ខ្ញុំក៏បាន ខ្ញុំជាអ្នកត្រូវការដោយជីវិត ក៏មិនអាចនឹងលះបង់នូវដើមឈើនោះចោលឡើយ (បើខ្ញុំដឹងថាឈើនោះអស់ហើយ ៗ លះបង់ចោល) នុ៎ះ មិនមែនជាធម៌របស់សប្បុរសទេ ។*

*ស្ដេចសក្កៈបានស្ដាប់ពាក្យរបស់ស្ដេចសេកនោះហើយ មានចិត្តត្រេកអរ ត្រាស់សរសើរ កាលប្រាថ្នានឹងឲ្យពរ ទើបពោល ២ គាថា ថា*

សាធុ សក្ខិ កតំ ហោតិ, មេត្តិ សំសតិ សន្ថវោ;
សចេតំ ធម្មំ រោចេសិ, ចាសំសោសិ វិជានតំ។

*ម្នាលបក្សី សេចក្តីមេត្រី សេចក្តីជួបជុំ និងសេចក្តីស្និទ្ធស្នាល ដែលអ្នកបានធ្វើហើយ ជាការប្រពៃណាស់ បើអ្នកពេញចិត្តនឹងធម៌នោះ អ្នកនឹងបានជាទីសរសើរនៃពួកវិញ្ញូជន ។*

សោ តេ សុវ វរំ ទម្មិ, បត្តយាន វិហង្គម;
វរំ វរស្សុ វក្កង្គ, យំ កិញ្ចិ មនសិច្ឆសិ។

*ម្នាលសេក អ្នកមានស្លាបជាយាន ហើរទៅឰដ៏អាកាស យើងឲ្យពរដល់អ្នក ម្នាលបក្សី បើអ្នកមានចិត្តប្រាថ្នានូវពរណាមួយ ចូរទទួលយកនូវពរនោះចុះ ។*

*ស្តេចសេកស្តាប់ពាក្យនោះហើយ កាលទទួលពរ ទើបពោលគាថាទី ៧ ថា*

វរញ្ច មេ ហំស ភវំ ទទេយ្យ, អយញ្ច រុក្ខោ បុនរាយុំ លភេថ;
សោ សាខវា ផលិមា សំវិរូឡ្ហោ, មធុត្ថិកោ តិដ្ឋតុ សោភមានោ។

*ម្នាលហង្ស អ្នកគប្បីឲ្យពរដល់ខ្ញុំ សូមឲ្យដើមឈើនេះ ត្រឡប់មានអាយុរស់វិញ សូមឲ្យដើមឈើនោះ មានមែក មានផ្លែ លូតលាស់ល្អ មានផ្លែ មានរសផ្អែមល្អ ។*

*លំដាប់នោះ សក្កទេវរាជកាលឲ្យពរ ទើបពោលគាថាទី ៨ ថា*

តំ បស្ស សម្ម ផលិមំ ឧឡារំ, សហាវ តេ ហោតុ ឧទុម្ពរេន;
សោ សាខវា ផលិមា សំវិរូឡ្ហោ, មធុត្ថិកោ តិដ្ឋតុ សោភមានោ។

*ម្នាលសម្លាញ់ អ្នកចូរមើលដើមឈើ ដែលមានផ្លែដ៏លើសលុបនេះចុះ ទីលំនៅរបស់អ្នក ចូរកើតជាមួយនឹងដើមល្វា ដើមល្វានោះ ចូរមានមែក មានផ្លែលូតលាស់ល្អ មានផ្លែ មានរសផ្អែមល្អ ។*

*បណ្ដាបទទាំងនោះ បទថា* **សហាវ តេ ហោតុ ឧទុម្ពរេជា** *សេចក្ដីថា ការនៅជាមួយនឹងដើមល្វាចូរមានដល់លោក ។*

*ស្ដេចសក្កៈកាលពោលយ៉ាងនេះហើយ ក៏លះបង់អត្តភាពនោះ សម្ដែងអានុភាពរបស់ខ្លួន និងនាងសុជា កាន់យកទឹកដោយដៃពីទន្លេគង្គា ស្រោចជង្គត់ដើមល្វា ។ ក្នុងពេលនោះឯង ដើមល្វាក៏ដល់ព្រមដោយមែកនិងប្រគាប មានផ្លែផ្អែម តាំងឡើង បិតនៅយ៉ាងស្រស់បំព្រង ហាក់ដូចជាមុណ្ឌមណិបព៌ត ។ ស្ដេចសេកឃើញដើមឈើនោះហើយ ក៏មានសេចក្ដីសោមនស្ស កាលធ្វើការសរសើរដល់សក្កទេវរាជ ទើបពោលគាថាទី ៩ ថា*

**ឯវំ សក្ក សុខី ហោហិ, សហ សព្ពេហិ ញាតិភិ,**
**យថាហមជ្ជ សុខិតោ, ទិស្វាន សផលំ ទុមំ។**

*បពិត្រសក្កៈ កាលបើយ៉ាងនេះ សូមឲ្យព្រះអង្គបានសេចក្ដីសុខ ព្រមទាំងពួកញាតិទាំងអស់ ឲ្យដូចខ្ញុំដែលបានសេចក្ដីសុខ ព្រោះបានឃើញដើមឈើ ប្រកបដោយផ្លែ ក្នុងថ្ងៃនេះឯង ។*

*ចំណែកសក្កទេវរាជកាលឲ្យពរដល់ស្ដេចសេកនោះហើយ ក៏បានធ្វើដើមល្វាឲ្យមានផ្លែជាប់ជានិច្ច ហើយទើបទៅកាន់ឋានរបស់ខ្លួន ជាមួយនឹងនាងសុជា ។*

*ព្រះសាស្ដាកាលសម្ដែងសេចក្ដីនោះ ទ្រង់ក៏តម្កល់អភិសម្ពុទ្ធគាថា ថា*

**សុវស្ស ច វរំ ទត្វា, កត្វាន សផលំ ទុមំ;**
**បក្កាមិ សហ ភរិយាយ, ទេវានំ នន្ទនំ វនំ។**

*ព្រះឥន្ទបានឮពាក្យសេកហើយ ក៏ធ្វើនូវដើមឈើនោះ ឲ្យមានផ្លែ រួចចៀសចេញទៅកាន់នន្ទនវនឧទ្យានរបស់ពួកទេវតា ជាមួយនឹងភរិយា ។*

ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុ បោរាណកបណ្ឌិតទាំងឡាយសូម្បីកើតក្នុងកំណើតសត្វតិរច្ឆាន ក៏លះសេចក្តីល្មោភក្នុងអាហារ ។ ព្រោះហេតុអ្វី អ្នកដែលបានបួសក្នុងសាសនាមានសភាពបែបនេះហើយ ក៏នៅប្រព្រឹត្តល្មោភអាហារទៀត អ្នកចូរទៅ ហើយនៅក្នុងទីនោះចុះ ដូច្នេះហើយ ទ្រង់សម្តែងកម្មដ្ឋានដល់ភិក្ខុនោះ ហើយប្រជុំជាតក ។ ភិក្ខុនោះ ទៅក្នុងទីនោះ កាលចម្រើនវិបស្សនា ក៏បានសម្រេចព្រះអរហត្ត ។

**តទា សក្កោ អនុរុទ្ធោ អហោសិ** ស្តេចសក្កៈក្នុងកាលនោះ បានមកជា អនុរុទ្ធ

**សុវរាជា បន អហមេវ អហោសឹ** ចំណែកស្តេចសេក គឺ តថាគត នេះឯង ។

ចប់ មហាសុវរាជ ៕

( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក នវកនិបាត បិដកលេខ ៥៩ ទំព័រ ១៣៩)

ថ្ងៃអង្គារ ១០ កើត ខែវិសាខ ឆ្នាំច សំរិទ្ធិស័ក ច.ល. ១៣៨០

ថ្ងៃទី ២៤ ខែមេសា ព.ស. ២៥៦១ គ.ស.២០១៨

ដោយ ស.ដ.វ.ថ.